# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីអវិជ្ជាក្នុងព្រះពុទ្ធសាសនានិងអវិជ្ជាតាមន័យផ្លូវលោក

web site: hoksavann.org

ថ្ងៃទី១១ មិថុនា ២០០៥

អវិជ្ជា តាមន័យរបស់ព្រះពុទ្ធសាសនា ជាសភាវធម៌សំដៅយកការមិនដឹងនូវអរិយសច្ច៤គឺ មិនដឹងនូវទុក្ខ មិនដឹងនូវហេតុដែលនាំឲ្យកើតទុក្ខ មិនដឹងនូវទីរំលត់ទុក្ខ មិនដឹងនូវផ្លូវប្រតិបត្តិទៅកាន់ទីរំលត់ទុក្ខ ។ អវិជ្ជាជានាមធម៌ ពុំមែនជារូបធម៌ ជាដីទឹកភ្លើងខ្យល់ឡើយ គឺជាគំនិតដែលយល់ខុស បើគំនិតយល់ត្រូវហៅថាមានវិជ្ជា គឺមានចំណេះយល់ច្បាស់ក្នុងអរិយសច្ច៤ ។ អវិជ្ជាផ្លូវធម៌ផ្សេងពីអវិជ្ជាផ្លូវលោក ។ អវិជ្ជាផ្លូវលោក សំដៅយកការពុំចេះដឹងនូវវិជ្ជាទាំងឡាយ ដែលមនុស្សលោកបង្កើតឡើង ដូចជាពុំចេះអក្សរសាស្ត្រ ពុំចេះប្រវត្តិសាស្ត្រ ភូមិសាស្ត្រ ចរិយាសាស្ត្រ ទស្សនវិជ្ជា និងបច្ចេកវិជ្ជាផ្សេងៗជាដើម ។ ឯអវិជ្ជាផ្លូវធម៌ ពុំមែនល្ងង់ព្រោះពុំចេះវិជ្ជាទាំងនេះទេ ព្រោះវិជ្ជាផ្លូវលោកទាំងនេះ មានភាពពិតតាមលោកសច្ចៈ ។ អ្នកមានវិជ្ជាផ្លូវលោកទាំងនេះ ពុំឈ្មោះថាអស់អវិជ្ជាឡើ-យ គឺនៅមានអវិជ្ជាដដែល អវិជ្ជាព្រោះពុំដឹងនូវអរិយសច្ចដែលធ្វើទុក្ខឲ្យអស់ទៅមានជាតិទុក្ខជាដើម ។ អវិជ្ជាពុំដឹងថាខ្លួនរបស់មនុស្សសត្វចែកជាខន្ធ៥គឺរូបវេទនា សញ្ញា សង្ខារ និង វិញ្ញាណ ដែលប្រព្រឹត្តទៅដោយលក្ខណៈ៣យ៉ាងគឺ អនិច្ចំ ពុំទៀងជាទុក្ខនិងជាអនត្តា ពុំមែនខ្លួនប្រាណ ។ ព្រះពុទ្ធសំដែងថា សេចក្តីល្ងង់អ្វីពុំស្មើនឹងសេចក្តីល្ងង់ក្នុងខន្ធ៥ឡើយ ។ ការស្គាល់លក្ខណៈខន្ធ៥ទើបធ្វើទុក្ខឲ្យអស់ទៅបាន ។ វិជ្ជាផ្លូវលោកគ្រាន់តែជួយសំរួលឲ្យរស់នៅក្នុងសង្គមបានសុខស្រួលខ្លះប៉ុណ្ណោះ ប៉ុន្តែពុំអាចធ្វើទុក្ខមានជាតិទុក្ខជាដើមឲ្យអស់ទៅបានឡើយ ចំណែកការមានវិជ្ជាក្នុងខន្ធ៥ផ្នែកវិបស្សនាវិជ្ជាទើបធ្វើទុក្ខឲ្យអស់ទៅបាន ។ អវិជ្ជាកន្លែងខ្លះវិគ្គហៈថាធម្មជាតិបាននូវអំពើដែលគេមិនចង់បាន បានដល់ទុច្ចរិត៣យ៉ាងគឺ កាយទុច្ចរិត វចីទុច្ចរិត និងមនោទុច្ចរិត ។ មួយទៀតថា ធម្មជាតិមិនបាននូវអំពើដែលគេត្រូវបាន បានដល់សុចរិត៣យ៉ាងគឺ កាយសុចរិត វចីសុចរិត និង មនោសុចរិត ។ អវិជ្ជាពុំដឹងនូវវត្ថុ៨ប្រការ គឺអរិយសច្ច៤ ហើយបន្ថែម៤ខាងចុងគឺ ពុំដឹងនូវខន្ធអតីតៈ ពុំដឹងនូវខន្ធអនាគត ពុំដឹងនូវខន្ធទាំងអតីតៈនិងអនាគត និងមិនដឹងនូវបដិច្ចសមុប្បាទធម៌ គឺធម៌កើតរលត់តគ្នាដោយហេតុ ដោយបច្ច័យ ដូចជាអវិជ្ជាកើតមាន នាំឲ្យមានសង្ខាររហូតជាតិកើតមាននាំឲ្យមានជរានិងមរណៈជាដើម ។ ព្រះពុទ្ធសំដែងថា តថាគតរកពុំឃើញធម៌ណាមួយ ដែលមានទោសដូចអវិជ្ជានេះឡើយ ។ អវិជ្ជាមានទោសធ្ងន់ជាងធម៌ដទៃ ដោយហេតុថា មនុស្សសត្វដែលធ្វើខុសដោយសារអវិជ្ជា ការពុំដឹងនូវអរិយសច្ច៤ គឺពុំដឹងនូវទុក្ខ នូវហេតុដែលនាំឲ្យកើតទុក្ខជាដើមនេះឯង ប្រៀបដូចមនុស្សងងឹតភ្នែកពីកំណើតហើយវង្វេងផ្លូវក្នុងព្រៃ តែងតែដើរខុសផ្លូវជាធម្មតា ។ អវិជ្ជាប្រៀបដូចសត្វមមាចមមង់ដែលឃើញអណ្តាតភ្លើងភ្លឺថា ក៏ស្មានខុសថាជាពន្លឺគួរជាទីគួររីករាយសប្បាយ ឥតបានដឹងថាភ្លើងនោះក្តៅក៏ហើរចូលទៅដល់នូវការក្សិណក្ស័យជីវិត ។ ប្រៀបម៉្យាងទៀត ដូចសត្វដង្កូវនាងដែលរុំព័ទ្ធខ្លួននៅក្នុងសំបុក បានត្រូវគេយកទៅស្ងោរ ដើម្បីយកសរសៃសូត្រដែលរុំព័ទ្ធខ្លួនវា ធ្វើជាសូតត្បាញធ្វើជាសំពត់ស្លៀកពាក់ ក៏ក្ស័យជីវិតទៅ ។ សេចក្តីទាំងអស់នេះ ប្រៀបដូចជាបុគ្គលប្រកបដោយអវិជ្ជាបិទបាំងពុំឲ្យឃើញការពិត ហើយប្រព្រឹត្តធ្វើតាមការយល់ខុសនោះ ក៏ដល់នូវសេចក្តីវិនាសទៅ ។

អវិជ្ជាអាចកំចាត់បង់បានដោយការសិក្សាព្រះធម៌ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ហើយប្រតិបត្តិតាមសមថៈវិបស្សនា ឲ្យឃើញអរិយសច្ចៈទាំង៤ពន្លះមគ្គផលនិព្វានរហូតអរហត្តផល ។ ពុទ្ធសាសនិកជនដែលបានសិក្សាយល់ច្បាស់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ទោះបីពុំអាចលះបង់អវិជ្ជានេះបានក្នុងរយៈពេលនេះ ក៏ឈ្មោះថាបានដើរត្រូវតាមផ្លូវដែលត្រូវចេះហើយ ។ អវិជ្ជាបិទបាំងមិនឲ្យឃើញការពិតនេះ មានទោសទាំងផ្លូវលោកទាំងផ្លូវធម៌ ។៚

⌘